# QE Import-Export

## User Manual

រៀបចំដោយៈ Speedaccount

លេខទូរស័ព្ទៈ ( +855 ) 70 606666

អ៊ីមែលៈ qe@speedaccount.com

វេបសាយៈ www.speedaccount.com

# មាតិកា


- I.ចំណុចចាប់ផ្តើម ..... 3
- II.របៀប បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ..... 4
- III.របៀប បញ្ជូនទិន្នន័យពី Excel ចូលទៅក្នុង QuickBooks ..... 12
- IV.ប្រវត្តិប្រតិបត្តិការ ..... 17

# I. ចំណុចចាប់ផ្តើម

- **ជំហានទី១**

សូមធ្វើការបើកដំណើរការកម្មវិធី QuickBooks ជាមុនសិនមុនពេលបើកដំណើរការកម្មវិធី QE Export/Import Tool ដើម្បីទាញយកទិន្នន័យពី QuickBooks Company ដែលមានរូបិយប័ណ្ណគោលជាប្រាក់ដុល្លារ USD ទៅបញ្ចូលក្នុង QuickBooks Company ថ្មីដែលមានរូបិយប័ណ្ណគោលជាប្រាក់រៀល KHR ។

- **ជំហានទី២**

បន្ទាប់ពីលោកអ្នកធ្វើការបើកកម្មវិធី QuickBooks រួចរាល់ហើយ សូមធ្វើការបើកកម្មវិធី QE Export\Import Tool ដើម្បីធ្វើការ បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ឬ បញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks ។



# II. របៀប បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel

- ដើម្បីធ្វើការបញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel សូមធ្វើតាមការណែនាំខាងក្រោម៖

    ❶ សូមចុចលើប៊ូតុង **បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel**

បន្ទាប់មកនឹងមានលោតផ្ទាំងមួយនៅកម្មវិធី QuickBooks ដើម្បីអោយលោកអ្នកធ្វើការអនុញ្ញាតអោយកម្មវិធី **QE Import-Export Tool** អាចដំណើរការបានជាមួយកម្មវិធី QuickBooks ដោយធ្វើតាមការណែនាំខាងក្រោម៖



▪ សូមធ្វើការជ្រើសរើសយក៖

❷ "Yes, always; allow access even if QuickBooks is not running"

❸ បន្ទាប់មកសូមធ្វើការ ធីក (√) យក"Allow this application to access personal data such as Social Security Number and Customer credit card information."

❹ រួចចុចលើប៊ូតុង Continue…



❺ ចុចលើប៊ូតុង Yes ដើម្បីបញ្ជាក់ការអនុញ្ញាតអោយ **QE Export-Import Tool** ដំណើរការជាមួយ QuickBooks (រូបទី១)

❻ បន្ទាប់មកចុចប៊ូតុង Done ជាការស្រេច(រូបទី២)

(រូបទី ១) (រូបទី ២)







- បន្ទាប់មកទៀតក្នុងកម្មវិធី **QE Import-Export Tool** សូមធ្វើការកំណត់នៅក្នុងប្រអប់ ជម្រើសទាញយក ដើម្បីបញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ដូចខាងក្រោម៖

❶ សូមធ្វើការជ្រើសរើសប្រភេទទិន្នន័យដើម្បីធ្វើការបញ្ជូនទិន្នន័យទៅកាន់ Excel

- All : ទាញយកទិន្នន័យទាំងអស់
- Master : ទាញយកតែទិន្នន័យ Master
- Transaction : ទាញយកតែទិន្នន័យ Transaction ( ប្រតិបត្តិការ )
- Custom : ទាញយកទិន្នន័យតាមការជ្រើសរើស

❷ សូមធ្វើការជ្រើសរើសកាលបរិច្ឆេទដើម្បីបញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel

- **គិតត្រឹមថ្ងៃ ៖** ជម្រើសទាញយកទិន្នន័យពីថ្ងៃចាប់ផ្ដើមរហូតដល់កាលបរិច្ឆេទជាក់លាក់ណាមួយ
- **ចន្លោះថ្ងៃ ៖** ជម្រើសទាញយកទិន្នន័យពីកាលបរិច្ឆេទជាក់លាក់ណាមួយរហូតដល់កាលរិច្ឆេទជាក់លាក់ណាមួយទៀតដែលយើងចង់បាន

❸ **រូបិយប័ណ្ណគោលដូចគ្នា** : ចំពោះរូបិយប័ណ្ណលោកអ្នកអាចធ្វើការ បញ្ជូនទិន្នន័យទៅកាន់ Excel ដោយរក្សាទុកនូវរូបិយប័ណ្ណរបស់លោកអ្នកដដែល

❹ **រូបិយប័ណ្ណគោលផ្សេងទៀត** : លោកអ្នកក៏អាចធ្វើការ បញ្ជូនទិន្នន័យទៅកាន់ Excel ដោយផ្លាស់ប្ដូរពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយ តាមរយៈការវាយបញ្ចូលនូវអត្រាប្ដូរប្រាក់ដោយខ្លួនឯង។ សូមចុចលើប៊ូតុង




ដើម្បីបញ្ចូលអត្រាប្ដូរប្រាក់។

❺ សូមចុចលើប៊ូតុង




ដើម្បីបញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ដូចខាងក្រោមនេះ ៖

❻ សូមចុចលើប៊ូតុង




បើសិនជាលោកអ្នកចង់មើលពីរបៀប បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel


Import-Export Tool / បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel
ព័ត៌មាន QuickBooks ដែលកំពុងភ្ជាប់
ឈ្មោះ QBE IO
រូបិយប័ណ្ណគោល US Dollar
អាសយដ្ឋាន Toul Sangkae, Reussei Keo, Phnom Penh
ទីតាំងឯកសារ D:\QE Extension\QE DB\Master Gain\QBE IO.qbw
ជម្រើសទាញយក
1
ប្រភេទទិន្នន័យ All
2
គិតត្រឹមថ្ងៃ 2020-12-31
ចន្លោះថ្ងៃ
ជម្រើសរូបិយប័ណ្ណគោល
QuickBooks នេះប្រើប្រាស់រូបិយប័ណ្ណ US Dollar ជារូបិយប័ណ្ណគោល។
តើអ្នកចង់ធ្វើការទាញយកទិន្នន័យនេះដើម្បីដាក់ចូលក្នុង QuickBooks ដែលមានរូបិយប័ណ្ណគោល US Dollar ដូចគ្នាឬ រូបិយប័ណ្ណគោលផ្សេងទៀត?
3
រូបិយប័ណ្ណគោលដូចគ្នា (US Dollar)
រូបិយប័ណ្ណគោលផ្សេងទៀត
4
Cambodian Riel
អត្រាប្តូរប្រាក់
ឈ្មោះទិន្នន័យ
6
ជំនួយ
5
យល់ព្រម
ចាកចេញ

❼ បន្ទាប់មកទៀត កម្មវិធីនឹងដំណើរការ Export ទិន្នន័យពី QuickBooks ដោយស្វ័យប្រវត្តិ ដូចខាងរូបភាពខាងក្រោមនេះ ៖



❽ បន្ទាប់ពីដំណើរការ បញ្ចូនទិន្នន័យទៅ Excel បានជោគជ័យ សូមជ្រើសរើសទីតាំង និងចុចលើប៊ូតុង 

ដើម្បីរក្សាទុកទិន្នន័យដែលបានបញ្ចូនរួចរាល់



❾ ក្នុងករណីដែលដំណើរការ បញ្ជូនទិន្នន័យទៅកាន់ Excel បានជោគជ័យ ប៉ុន្តែលោកអ្នកមិនបានចុចប៊ូតុង Save ហើយបែរជាចុចប៊ូតុង Cancel លោកអ្នកនៅតែអាចទាញយកឯកសារដែលបាន បញ្ជូនទៅ Excel រួចរាល់ ដោយគ្រាន់តែចុចលើប៊ូតុង [ទាញយក] និងជ្រើសរើសទីតាំងទុកឯកសារជាការស្រេច។

❿ ចុចលើប៊ូតុង [ចាកចេញ] ដើម្បីត្រឡប់ទៅទំព័រដើមវិញ។



# III. របៀប បញ្ជូនទិន្នន័យពី Excel ចូលទៅក្នុង QuickBooks

- ដើម្បីធ្វើការបញ្ជូនទិន្នន័យពី Excel ចូលទៅក្នុង QuickBooks សូមធ្វើតាមការណែនាំខាងក្រោមខាងក្រោម៖

❶ សូមចុចលើប៊ូតុង 




- សូមធ្វើការជ្រើសរើសយក៖

  ❷ ″Yes, always; allow access even if QuickBooks is not running″

  ❸ បន្ទាប់មកសូមធ្វើការ ធីក (√) យក″Allow this application to access personal data such as Social Security Number and Customer credit card information.″

  ❹ រួចចុចលើប៊ូតុង Continue…

(រូបទី ១)




(រូបទី ២)



❸ បន្ទាប់មក សូមចុចលើប៊ូតុង ស្វែងរក ដើម្បីចូលទៅយកឯកសារដែលលោកអ្នកត្រូវធ្វើការ **បញ្ចូនទិន្នន័យចូលទៅក្នុង** QuickBooks របស់លោកអ្នក។



❹ បន្ទាប់មក សូមចុចលើប៊ូតុង [ពិនិត្យទិន្នន័យ] ដើម្បីពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ មុននឹងធ្វើការ **បញ្ជូនទិន្នន័យពី Excel ចូលទៅក្នុង QuickBooks** របស់លោកអ្នក។

❺ ប្រសិនបើទិន្នន័យណាមានបញ្ហា វានឹងបង្ហាញចំនួនទិន្នន័យនោះនៅជួរឈរ (**កំហុស**)។ ឧទាហរណ៍ ទិន្នន័យ Pay Bills ត្រឹមត្រូវ នោះលោកអ្នកត្រូវធ្វើការកែប្រែដើម្បីធ្វើការបញ្ជូនទិន្នន័យម្តងទៀត។

❻ លោកអ្នកក៏នៅតែអាចបញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks បានដូចគ្នាដោយជ្រើសរើសតាមជម្រើសខាងក្រោម៖

- **អនុញ្ញាតបញ្ជូនតែទិន្នន័យជោគជ័យ** : ជម្រើសនេះនឹងលើកលែងការព្រមាន និងកំហុសទិន្នន័យ ដែលលោកអ្នកអាចបញ្ជូនតែទិន្នន័យជោគជ័យក៏បាន។
- **តាមស្តង់ដារ QuickBooks** : ជម្រើសនេះអាចអោយលោកអ្នកបញ្ជូនទិន្នន័យដែលមិនត្រឹមត្រូវដោយធ្វើការផ្លាស់ប្តូរស្តង់ដារពុម្ពគំរូរបស់ QuickBooks។

❼ សូមចុចលើប៊ូតុង [ជំនួយ] បើសិនជាលោកអ្នកចង់មើលពីរបៀប បញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks ។

❽ ចុចលើប៊ូតុង [យល់ព្រម] ដើម្បីធ្វើការ បញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks



❾ លោកក៏អ្នកអាចទាញយកទិន្នន័យណាដែលមានបញ្ហា ដើម្បីយកទៅកែប្រែអោយត្រឹមត្រូវវិញដោយគ្រាន់តែចុចលើប៊ូតុង ទាញយកទិន្នន័យ បន្ទាប់មកជ្រើសរើសយក "**ទាញយកទិន្នន័យមិនត្រឹមត្រូវ**"

❿ បន្ទាប់ពីលោកអ្នកកែប្រែទិន្នន័យត្រឹមត្រូវអស់ហើយ សូមចុចប៊ូតុង ពិនិត្យទិន្នន័យ ម្តងទៀតដើម្បីផ្ទៀតផ្ទាត់ទិន្នន័យ បន្ទាប់មកចុចប៊ូតុង យល់ព្រម ដើម្បី**បញ្ចូលទិន្នន័យពី Excel ទៅកាន់ QuickBooks** ជាការស្រេច។

⓫ ចុចលើប៊ូតុង ចាកចេញ ដើម្បីត្រឡប់ទៅទំព័រដើមវិញ។



# IV. ប្រវត្តិប្រតិបត្តិការ

❶ ដើម្បីមើលពីប្រវត្តិដែលលោកអ្នកធ្លាប់ធ្វើការ បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ឬ បញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks សូមចុចលើប៊ូតុង 




❷ ត្រង់ចំណុចនេះលោកអ្នកអាចមើលលំអិតពីប្រវត្តិដែលលោកអ្នកធ្វើការ បញ្ជូនទិន្នន័យពី QuickBooks ទៅកាន់ Excel ឬ បញ្ជូនទិន្នន័យពី Excel ទៅកាន់ QuickBooks ដូចខាងក្រោម៖



❸ ត្រង់ចំណុចនេះលោកអ្នកក៏អាចទាញយក ទិន្នន័យដែលបញ្ជូនពី QuickBooks ទៅកាន់ Excel បានផងដែរដោយគ្រាន់តែចុចលើសញ្ញា **ចុចបី** (...) បន្ទាប់មកចុចលើពាក្យ **ទាញយក**

❹ ចុចលើប៊ូតុង [ចាកចេញ] ដើម្បីត្រឡប់ទៅទំព័រដើមវិញ។




| កាលបរិច្ឆេទ | ក្រុមហ៊ុន | ប្រភេទប្រតិបត្តិការ | ទីតាំងឯកសារ Excel | សកម្មភាព |
|---|---|---|---|---|
| 11/03/21 | Cambodain16 | ទាញទិន្នន័យ | D:\Bill24\qb_extension\Qe Master\h60 | ... |
| 11/03/21 | Cambodain16 | ទាញទិន្នន័យ | D:\Bill24\qb_extension\Qe Master\h60 | ... |
| 17/03/21 | Cambodain16 | ទាញទិន្នន័យ | D:\Bill24\qb_extension\Qe Master\h60 | ... |
| 20/03/21 | Master Gain | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 20/03/21 | Master Gain | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 20/03/21 | Master Gain | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 20/03/21 | Master Gain | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 20/03/21 | Master Gain | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 20/03/21 | Company template | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 21/03/21 | QBE IO | ទាញទិន្នន័យ | D:\UAT\QE Import and Export\Release | ... |
| 17/03/21 | Cambodain16 | បញ្ជូនទិន្នន័យ | - | ... |